00360104

E2/14/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 08 / 2009
ម៉ោង (Time/Heure): 15 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

---

# សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញពាក់ព័ន្ធនឹងភស្តុតាងនៃអត្តសញ្ញាណ ចាំបាច់ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (E2/36)

---

**សហព្រះរាជអាជ្ញា**

ជាលាង
Robert PETIT

**ជនជាប់ចោទ**

កាំង ហ្កេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៨-៩១៤ ទូរសារ: (៨៥៥)-២៣-២១៨-៩៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau , Dangkao Phnom Penh Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

00360105

E2/94/4

០០១/១៨ កក្កដា ២០០៧/អវតក/អជសជ

I. **អំពីអង្គហេតុ**

១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ ស្នើសុំឲ្យមានការពិចារណាឡើងវិញអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩ ដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានច្រានចោលពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36[1]។ នៅថ្ងៃ ទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36, E2/51 និង E2/69 ត្រូវបានអង្គជំនុំជម្រះបង្គាប់ឲ្យដាក់ជូនភស្តុតាងបន្ថែមដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់ពួកគាត់រហូតដល់ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩[2]។

២. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាឯកសារដែលអ្នកដាក់ពាក្យសុំ E2/36 បានដាក់ គឺមិនគ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីអត្តសញ្ញាណរបស់គាត់ឡើយ ហើយមិនមានព័ត៌មានបញ្ជាក់បន្ថែមត្រូវបានដាក់ជូនអង្គជំនុំជម្រះនៅក្នុងកាលបរិច្ឆេទដែលបានកំណត់ឡើយ[3]។ មានការស្នើសុំឲ្យពិចារណាឡើងវិញពីព្រោះសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានលើកឡើងថាពួកគេឥឡូវ

---

[1] "សំណើសុំឲ្យពិចារណាឡើងវិញ ពាក់ព័ន្ធនឹងភស្តុតាងនៃអត្តសញ្ញាណចាំបាច់ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (E2/36)" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E2/94/3) ("សំណើ")។

[2] "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាងលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ (ឯកសារ E2/94)។ សូមអាន "ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [E2/36]" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ (ឯកសារ E2/36)។

[3] "សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្នកដាក់ពាក្យសុំ E2/36, E2/51 និង E2/69" ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E2/94/2)។

នេះមានគោលជំហរផ្តល់នូវភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីអត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36។ អត្តសញ្ញាណថតចម្លងមួយច្បាប់ត្រូវបានផ្តល់ជូនអង្គជំនុំជម្រះជាមួយនឹងសំណើសុំឲ្យមានការពិចារណាឡើងវិញ[4]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី៣ បានលើកនូវផលវិបាកក្នុងការស្វែងរក និងទាក់ទងជាមួយអ្នកដាក់ពាក្យសុំដែលជាមូលហេតុក្នុងការខកខានមិនបានប្រតិបត្តិតាមកាលបរិច្ឆេទដែលមានចែងនៅក្នុងវិធាន និងដែលបានកំណត់ ដោយអង្គជំនុំជម្រះ[5]។

## II. **អំពីសំអាងហេតុ**

៣. វិធាន ២៣(៤) នៃវិធានផ្ទៃក្នុងចែងថា ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ជូនយ៉ាងយូរបំផុតរយៈពេល១០(ដប់)ថ្ងៃ មុនកាលបរិច្ឆេទនៃសវនាការបឋម។ ដើម្បីអាចទទួលយកបាន ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីអត្តសញ្ញាណផងដែរ។ ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36 ត្រូវបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។ សវនាការបឋមចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលសវនាការនេះត្រូវបានកំណត់ពេលវេលានៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩[6]។ ដោយហេតុផលនៃស្ថានភាពពិសេស អង្គជំនុំជម្រះសាលាដំបូងបានផ្តល់នូវពេលវេលាបន្ថែមដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីខាងលើដើម្បីនឹងធ្វើ

---

[4] ឧបសម្ពន្ធ១ : អត្តសញ្ញាណប័ណ្ណ របស់ [E2/36] (ឯកសារ E2/94/3.1)។

[5] "សំណើសុំឲ្យពិចារណាឡើងវិញ ពាក់ព័ន្ធនឹងសក្តិភាពនៃអត្តសញ្ញាណចាំបាច់ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (E2/36)" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E2/94/3)។

[6] សេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសវនាការបឋម ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ (ឯកសារ E8)។

E2/94/4



ការបញ្ជាក់ភស្តុតាងអំពីអត្តសញ្ញាណ តាមរយៈសេចក្ដីសម្រេចចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០០៩[7]។

៤. អង្គជំនុំជម្រះកត់សំគាល់ឃើញថា នៅពេលធ្វើការសម្រេចច្រានចោលពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី E2/36 នោះ កាលបរិច្ឆេទក្នុងការដាក់ភស្តុតាងដើម្បីបញ្ជាក់ពីអត្តសញ្ញាណបានផុតកំណត់ហើយ។ ពេលវេលាគ្រប់គ្រាន់ត្រូវបានផ្ដល់ជូនសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣ដើម្បីទទួលបាននូវព័ត៌មាននេះ ។ ពួកគាត់មិនបានស្នើសុំការអនុញ្ញាតនៅចំពោះមុខអង្គជំនុំជម្រះដើម្បីពន្យារកាលបរិច្ឆេទនេះឡើយ។ ភាពអាចទទួលយកបានជាដើមបណ្ដឹងរដ្ឋប្បវេណី ស្របតាមវិធាន គឺជាបុព្វហេតុមួយសម្រាប់ជំហាននៃនីតិវិធីជាច្រើនទៀតនៅចំពោះមុខ អ.វ.ត.ក ដែលទាំងអស់នោះអាចប៉ះពាល់ដល់ដំណើរការឆាប់រហ័សនៃការជំនុំជម្រះក្ដី។ អង្គជំនុំជម្រះមានភារកិច្ចដឹកនាំដំណើរការនីតិវិធីស្របទៅនឹងករណីកិច្ចជាមូលដ្ឋានរបស់ខ្លួនក្នុងការធានាឲ្យមានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

៥. ជាចុងបញ្ចប់ អង្គជំនុំជម្រះកត់សំគាល់ឃើញថា ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក មិនបានចែងឲ្យមានការពិចារណាឡើងវិញឡើយសម្រាប់ជាដំណោះស្រាយចំពោះការបដិសេធពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ផ្ទុយទៅវិញ វិធានផ្ទៃក្នុង ២៣(៤), ១០៤(៤)(ឃ) និង ១០៧ បើកផ្លូវឲ្យប្ដឹងឧទ្ធរណ៍នៅក្នុងរយៈពេលកំណត់ ៣០ថ្ងៃ ទៅលើសេចក្ដីសម្រេចបដិសេធពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ អ្នកដាក់ពាក្យសុំមិនបានអនុវត្តសិទ្ធិនេះនៅក្នុងកាលបរិច្ឆេទដែលបានកំណត់ឡើយ។ សំណើសុំឲ្យពិចារណាឡើងវិញគឺត្រូវបានបដិសេធ។

---

[7] "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបញ្ជាក់ភស្តុតាងលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ (ឯកសារ E2/94)។

00360108

E2/94/4

០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

**ហេតុដូច្នេះសម្រេចៈ**

**បដិសេធ** សំណើនេះ។

ភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**